


# ដាក់ពាក្យសុំឥឡូវនេះ សម្រាប់ កម្មវិធីប័ណ្ណថ្លៃធ្វើដំណើរបញ្ចុះតម្លៃ ORCA LIFT

ORCA LIFT

Pierce Transit

**ឥឡូវនេះ មានមធ្យោបាយដែលអាចមានតម្លៃសមរម្យជាងមុន ដើម្បីជិះរថយន្ត Pierce Transit ទៅកាន់កន្លែងដែលអ្នកត្រូវការទៅ!**

## តើកម្មវិធី ORCA LIFT ដំណើរការយ៉ាងដូចម្តេច?

លោកអ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី **ORCA LIFT** ដើម្បីបង់ថ្លៃធ្វើដំណើរសម្រាប់មនុស្សពេញវ័យដែលបញ្ចុះតម្លៃ ប្រសិនបើលោកអ្នកបំពេញតាមតម្រូវការទាមទារភាពមានសិទ្ធិទទួលបានប្រាក់ចំណូលរហូតដល់ ឬស្មើនឹង 200% នៃកម្រិតភាពក្រីក្រសហព័ន្ធ (FPL)។ អ្នកជិះរថយន្តដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក៏អាចសន្សំប្រាក់លើសេវាកម្មរបស់ទីភ្នាក់ងារចូលរួមជាច្រើនទៀតនៅក្នុងតំបន់ **Puget Sound** ផងដែរ។ តម្រូវឱ្យមានសណ្ឋំបែបបទដែលអាចទទួលយកបាន ដើម្បីកំណត់សុពលភាពសិទ្ធិទទួលបានរបស់អ្នក។

## វិធីងាយៗដើម្បីបន្ថែមតម្លៃ!

- លោកអ្នកទទួលខុសត្រូវចំពោះការផ្ទុកប័ណ្ណ **ORCA LIFT** របស់អ្នកជាមួយនឹងតម្លៃ E-purse ឬសំបុត្រធ្វើដំណើរជិះរថយន្តគ្រាន់ស៊ីតដោយមានកម្មវិធី **myORCA**, តាមអនឡាញ ឬជួបដោយផ្ទាល់។
- ប័ណ្ណ **ORCA LIFT** ដំបូងរបស់អ្នកគឺឥតគិតថ្លៃ; ប័ណ្ណមួយមានរយៈពេលរហូតដល់ពីរឆ្នាំ។ ការប្តូរប័ណ្ណធ្វើដំណើរថ្មីតម្លៃ **$3** ដុល្លារ។
- ពិនិត្យមើលកន្លែងដែលលោកអ្នកអាចប្រើសាច់ប្រាក់ ប័ណ្ណឥណពន្ធ/ប័ណ្ណក្រេឌីត ឬមូលប្បទានប័ត្រឬសែកដើម្បីបន្ថែមតម្លៃ។ ចូលទៅវិបសាយ **info.myORCA.com/adding-value/** ឬហៅទូរស័ព្ទទៅលេខ **253.581.8000**, ជម្រើសទី **2**, បន្ទាប់មកជម្រើសទី **1**។

## ការធ្វើដំណើរក្នុងមួយជើងតម្លៃត្រឹមតែ $1 ដុល្លារប៉ុណ្ណោះ!

កម្មវិធីធ្វើដំណើរ Pierce Transit ទទួលយកការបង់ប្រាក់ថ្លៃសំបុត្រធ្វើដំណើរសម្រាប់មនុស្សពេញវ័យនៃកម្មវិធី **ORCA LIFT** ចំពោះសេវារថយន្តក្រុង និង Runner។ ឥឡូវនេះ វាកាន់តែមានតម្លៃសមរម្យសម្រាប់អ្នក ដើម្បីទៅធ្វើការ សាលារៀន ឬកន្លែងណាមួយដែលលោកអ្នកត្រូវការធ្វើដំណើរសាធារណៈ។ ដោយមានកម្មវិធី **ORCA LIFT** អ្នកជិះរថយន្តជាមនុស្សពេញវ័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងបង់ប្រាក់ធ្វើដំណើរការមួយជើង **$1** ដុល្លារតាម Pierce Transit។ សូមរីករាយជាមួយភាពងាយស្រួលចំពោះការប្រើប័ណ្ណ **ORCA** ដែលមានតម្លៃទាប។

## វិធីផ្សេងទៀតដើម្បីសន្សំប្រាក់៖

- ប័ណ្ណធ្វើដំណើរកម្មវិធី **ORCA LIFT** អាចមាននៅតាមសេវាកម្មរបស់ទីភ្នាក់ងារចូលរួមជាច្រើនទៀតនៅក្នុងតំបន់ Puget Sound។
- អ្នកជិះរថយន្តក៏អាចសន្សំប្រាក់លើលិខិតអនុញ្ញាតចត ដើម្បីជ្រើសរើសចំណតនិងជិះ Sound Transit និង King County Metro។
- ប័ណ្ណធ្វើដំណើរបញ្ចុះតម្លៃក៏អាចមានសម្រាប់មនុស្សចាស់ និងអ្នកជិះរថយន្តដែលមានពិការភាពផងដែរ។ យុវជនអាយុក្រោម 18 ឆ្នាំ ជិះជិះរថយន្តដោយឥតគិតថ្លៃ!

## ស្វែងយល់ថាតើលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការប្រើប្រាស់ប័ណ្ណ ORCA LIFT ដើម្បីបង់ថ្លៃសំបុត្រធ្វើដំណើររបស់អ្នកឬទេ!

**ស្កេនកូដ QR នេះ ដើម្បីមើលថាតើលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឬទេ។**

**ស្កេនកូដ QR នេះ ដើម្បីមើលប្រាក់ចំណូល FPL នាពេលបច្ចុប្បន្នដោយផ្អែកលើទំហំគ្រួសារ។**

សម្រាប់ជំនួយចុះឈ្មោះ សូមហៅទូរស័ព្ទលេខ **1.800.756.5437** ដាក់ពាក្យសុំតាមអនឡាញតាមរិបសាយ **info.myorca.com/LIFT** ឬ ដាក់ពាក្យសុំដោយផ្ទាល់នៅមជ្ឈមណ្ឌលណាមួយក្នុងចំណោមមជ្ឈមណ្ឌលចុះឈ្មោះចូលរួមនៅខោនធីភៀស **Pierce County ORCA LIFT**។

hola hello

**សេវាបកប្រែភាសា 253.581.8000**

español русский язык Việt
Tagalog 한국어 中文 ខ្មែរ

សូមស្វែងយល់បន្ថែមតាមវិបសាយ info.myORCA.com

PierceTransit.org • 253.581.8000 • TTY: 711